# ការប្ដេជ្ញារួមមួយ ដើម្បីអនុវត្តន៍អាជីវកម្ម ដែលការពារមនុស្ស និងភពផែនដីរបស់យើង ទាំងអស់គ្នា



## ក្រមប្រតិបត្តិ អ្នកផ្គត់ផ្គង់របស់យើងខ្ញុំ

Imperial Brands Supplier Code of Conduct | 15/08/2023

# ក្រមប្រតិបត្តិ
# អ្នកផ្គត់ផ្គង់របស់យើងខ្ញុំ

**នៅ Imperial Brands កេរ្តិ៍ឈ្មោះជាសាកលរបស់យើងខ្ញុំក្នុងនាមដៃគូដ៏មានទំនុកចិត្ត និងប្រកបដោយក្រមសីលធម៌ ហើយនិយោជកគឺជាធនធានមួយក្នុងចំណោមធនធានដ៏មានតម្លៃបំផុតរបស់យើងខ្ញុំ។**

យើងប្តេជ្ញាប្រតិបត្តិការប្រកបដោយការទទួលខុសត្រូវលើរាល់ការងាររបស់ខ្លួន ដោយគោរពមនុស្ស និងសហគមន៍របស់យើង និងភពផែនដី។ យើងមានគោលដៅយ៉ាងម៉ឺងម៉ាត់ជាស្រេចដើម្បីធានាថា យើងសម្រេចបានមហិច្ឆតាទាំងនេះ ហើយផ្នែកមួយនៃការប្តេជ្ញានេះគឺការធ្វើការងារជាមួយអ្នកផ្គត់ផ្គង់ដែលអាចទុកចិត្តបានដើម្បីស្វែងរកប្រភពផលិតផល និងសេវានានាប្រកបដោយអនុលោមភាព និរន្តរភាព និងមនសិការសង្គម។

ក្រមប្រតិបត្តិរបស់អ្នកផ្គត់ផ្គង់នេះដាក់ចេញនូវស្តង់ដារ អប្ប  បរមានៃអាកប្បកិរិយាដែលយើងរំពឹងពីអ្នកផ្គត់ផ្គង់ទាំងអស់របស់ Imperial Brands។ ក្រមប្រតិបត្តិរបស់អ្នកផ្គត់ផ្គង់នេះត្រូវបានធ្វើបច្ចុប្បន្នភាពក្នុងឆ្នាំ២០២៣ ដើម្បីឆ្លុះបញ្ចាំងពីការប្តេជ្ញាចំពោះនិរន្តរភាពរបស់យើងជាផ្នែកមួយនៃយុទ្ធសាស្ត្រ ESG របស់យើង។

មហិច្ឆតារបស់យើងមិនបញ្ឈប់ត្រឹមស្តង់ដារអប្បបរមានោះទេ។ យើងនឹងស្វះស្វែងដោះស្រាយរាល់អំពើទាំងឡាយដែលយើងគិតថា អាចបំពានលើក្រមនេះ ហើយយើងលើកទឹកចិត្តឲ្យអ្នកផ្គត់ផ្គង់របស់យើងទាំងអស់គ្នាស្វែងរកឱកាសដើម្បីអនុវត្តឲ្យលើសពីការរំពឹងទុកដូចមានចែងនៅក្នុងក្រមនេះដើម្បីឲ្យយើងអាចធ្វើឲ្យមានការផ្លាស់ប្តូរសង្គម និងបរិស្ថានជាវិជ្ជមានទាំងអស់គ្នា។

យើងខ្ញុំក៏សូមសំណូមពរថា ប្រសិនបើអ្នកមានក្តីកង្វល់ពិតប្រាកដ ឬសង្ស័យថា កើតមានអំពើរំលោភបំពានច្បាប់ សូមនិយាយចេញមក។ អ្នកអាចទាក់ទងយើងខ្ញុំតាមរយៈ៖

Imperial Brands Plc, 121 Winterstoke Road, Bristol BS3 2LL, United Kingdom
Tel៖ +44 (0) 117 963 6636
Email៖ SpeakUp@impbrands.com

ITG Brands have a distinct reporting line៖
ITG Brands បញ្ចេញមតិយោបល់
714 Green Valley Road
Greensboro, NC 27408
Tel៖ +1 866 447 6092

ឬលើកឡើងនូវក្តីកង្វល់របស់អ្នកជាសម្ងាត់ដោយប្រើប្រាស់សេវាបញ្ចេញមតិយោបល់ លើអនឡាញ។
យើងខ្ញុំប្តេជ្ញាជួយអ្នកលើដំណើររឿងនេះ និងធ្វើឲ្យមានការផ្លាស់ប្តូរជាវិជ្ជមាន។ សូមចូលរួមជាមួយពួកយើង។

Javier Huerta
ប្រធានគ្រប់គ្រងខ្សែសង្វាក់ផ្គត់ផ្គង់



# សេចក្តីផ្តើម

ក្រមប្រតិបត្តិអ្នកផ្គត់ផ្គង់របស់យើងខ្ញុំ ("ក្រមនេះ") ដាក់ចេញនូវស្តង់ដារអាកប្បកិរិយាដែលយើងរំពឹងអ្នកផ្គត់ផ្គង់របស់ Imperial Brands – ក្រុមហ៊ុន អ្នកផ្តល់សេវា ដៃគូអាជីវកម្មទាំងនោះដែលចូលរួមក្នុងទំនាក់ទំនងអាជីវកម្មផ្ទាល់ជាមួយ Imperial Brands និងបុត្រសម្ព័ន្ធក្រុមហ៊ុនរបស់យើងខ្ញុំ។

ក្រមនេះកំណត់គោលការណ៍ណែនាំស្វែងរកប្រភពប្រកបដោយការទទួលខុសត្រូវរបស់យើងខ្ញុំដូចបានកំណត់ខាងក្រោម និងរំលេចចេញនូវរបៀបដែលយើងខ្ញុំធ្វើការជាមួយអ្នកផ្គត់ផ្គង់របស់យើងដើម្បីស្វែងរកប្រភពផលិតផល និងសេវានានាប្រកបដោយអនុលោមភាព និរន្តរភាព និងមនសិការសង្គម។

ក្រមនេះក្តោបលើបីចំណុច៖

1. សុចរិតភាពអាជីវកម្ម – គេរំពឹងថា អ្នកផ្គត់ផ្គង់របស់យើងនឹងប្រកបដោយក្រមសីលធម៌ និងការទទួលខុសត្រូវ និងអនុវត្តរាល់ច្បាប់ និងបទប្បញ្ញត្តិជាធរមាន។
2. សិទ្ធិមនុស្ស និងភាពចម្រុះ សមធម៌ និងបរិយាបន្ន (DEI) – គេរំពឹងថា អ្នកផ្គត់ផ្គង់របស់យើងនឹងផ្តល់កន្លែងធ្វើការប្រកបដោយយុត្តិធម៌ និងសុវត្ថិភាព និងបង្ហាញនូវការគោរពសិទ្ធិមនុស្ស ភាពចម្រុះ សមធម៌ និងបរិយាបន្ន។
3. និរន្តរភាពបរិស្ថាន – គេរំពឹងថា អ្នកផ្គត់ផ្គង់របស់យើងនឹងដាក់ចេញនូវគោលនយោបាយ និងការអនុវត្តដែលការពារភពផែនដី និងកាត់បន្ថយផលប៉ះពាល់អវិជ្ជមានទៅលើបរិស្ថាន។



# អ្វីដែលយើងរំពឹងទុក

យើងរំពឹងថា អ្នកផ្គត់ផ្គង់របស់យើងនឹងបំពេញតាមស្តង់ដារអប្បបរមាដូចមានចែងនៅក្នុងក្រមនេះ និងលើសពីនេះ ក្នុងករណីដែលអាចធ្វើទៅបាន ឬតម្រូវដោយកិច្ចព្រមព្រៀងក្នុងកិច្ចសន្យា។ យើងក៏រំពឹងផងដែរថា អ្នកផ្គត់ផ្គង់របស់យើងនឹងខិតខំប្រឹងប្រែងដើម្បីធានាថា ដៃគូអាជីវកម្មផ្ទាល់របស់ខ្លួនបំពេញតាមស្តង់ដារធៀបនឹងស្តង់ដារអប្បបរមាដូចមានចែងនៅក្នុងក្រមនេះ។

- Imperial Brands ប្រើប្រាស់វិធីសាស្ត្រ "កែលម្អជាបន្តបន្ទាប់" ដើម្បីអនុវត្តស្តង់ដារទាំងនេះ។ យើងរំពឹងថា អ្នកផ្គត់ផ្គង់របស់យើងនឹងអាចបកស្រាយថា ពួកគាត់ធ្វើប្រតិបត្តិការយ៉ាងស៊ីសង្វាក់ទៅនឹងក្រមនេះ។ ក្នុងករណីសង្ស័យមានការបំពានណាមួយ យើងខ្ញុំអាចស្នើសុំឲ្យអ្នកផ្គត់ផ្គង់សហការដោយពិនិត្យផ្ទៃក្នុង ឬខាងក្រៅឡើងវិញ និងធ្វើការកែលម្អ។
- យើងទាំងអស់គ្នាទទួលបានអត្ថប្រយោជន៍ពីអាកប្បកិរិយាប្រកបដោយការទទួលខុសត្រូវ ពីព្រោះវាជាគន្លឹះឆ្ពោះទៅរកការថែរក្សាសង្គមមួយដែលអាចដំណើរការទៅបាន និងការពារទាំងកេរ្តិ៍ឈ្មោះរបស់យើង និងកេរ្តិ៍ឈ្មោះរបស់អ្នកផងដែរ។ ការអនុលោមតាមក្រមនេះ និងឆន្ទៈរបស់អ្នកផ្គត់ផ្គង់ក្នុងកាដោះស្រាយចំណុចខ្វះខាតនានាគឺជាគន្លឹះនៃការសម្រេចចិត្តរបស់យើងក្នុងការចូលរួម ឬបន្តទំនាក់ទំនងអាជីវកម្ម។
- ប្រសិនបើអ្នកមានសំណួរអំពីព័ត៌មាននៅក្នុងក្រមនេះ និងអ្វីដែលជាក្តីរំពឹងរបស់អ្នក សូមទាក់ទងមកតំណាងលទ្ធកម្មក្នុងស្រុករបស់អ្នក
- ប្រសិនបើអ្នកសង្កេតឃើញ ឬសង្ស័យអាកប្បកិរិយាណាមួយដែលផ្ទុយពីក្រមនេះ យើងខ្ញុំសូមលើកទឹកចិត្តឲ្យអ្នកនិយាយចេញមក។
- និយោជិតផ្ទាល់ និងភាគីពាក់ព័ន្ធខាងក្រៅទាំងអស់រួមមាន អ្នកផ្គត់ផ្គង់របស់យើង និងនិយោជិតរបស់ពួកគាត់អាចរកសេវាបញ្ចេញមតិយោបល់របស់យើងខ្ញុំ
- យើងខ្ញុំលើកទឹកចិត្តឲ្យអ្នកលើកស្ទួយសេវាបញ្ចេញមតិយោបល់ទៅដល់និយោជិតរបស់អ្នក និងតតិយជនណាមួយដែលធ្វើការតាងនាមឲ្យ Imperial Brands។
- អ្នកអាចឈ្វេងយល់បន្ថែមអំពីវិធីសាស្ត្របញ្ចេញមតិយោបល់ និងគោលនយោបាយមិនចងគំនុំនៅក្នុងគោលនយោបាយបញ្ចេញមតិយោបល់របស់យើងខ្ញុំ។





# គោលការណ៍ណែនាំស្វែងរកប្រភព ប្រកបដោយការទទួលខុសត្រូវរបស់យើងខ្ញុំ

ពួកយើងសុំឲ្យអ្នកផ្គត់ផ្គង់ និងដៃគូរបស់យើងចូលរួមក្នុងការ ប្ដេជ្ញាជាធ្លុងមួយទាំងអស់គ្នា។



**1**

យើងខ្ញុំប្ដេជ្ញាអនុវត្តរាល់ច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

**2**

យើងខ្ញុំប្ដេជ្ញាអនុវត្តប្រកបដោយការទទួលខុសត្រូវ និងដោយសុចរិតលើគ្រប់ផ្នែកនៃអាជីវកម្មរបស់ខ្លួន។

**3**

យើងខ្ញុំប្ដេជ្ញាគោរពសិទ្ធិមនុស្ស និងភាពចម្រុះ សមធម៌ និងបរិយាបន្ន (DEI) រួមមានសិទ្ធិទទួលបានកន្លែងធ្វើការដែលយុត្តិធម៌ អំណោយផលល្អ និងសុវត្ថិភាពសម្រាប់ទាំងអស់គ្នា។

**4**

យើងខ្ញុំប្ដេជ្ញាស្វែងរកប្រភពទំនិញ និងសេវានានាប្រកបដោយមនសិការ និងទទួលខុសត្រូវលើបរិស្ថានដោយសហការជាមួយអ្នកផ្គត់ផ្គង់របស់យើងដើម្បីធានាកែលម្អជាបន្តបន្ទាប់នៅក្នុងកិច្ចប្រឹងប្រែងនិរន្តរភាពរបស់ខ្លួន។



# ស្តង់ដារអប្បបរមារបស់យើងខ្ញុំ

ផ្នែកនៃក្រមនេះសង្ខេបស្តង់ដារអប្បបរមា ដែលអ្នកផ្គត់ផ្គង់របស់ Imperial Brands រំពឹងទុក។ ព័ត៌មានលម្អិតបន្ថែមមាននៅក្នុងផ្នែកបន្ទាប់។

## សុចរិតភាពអាជីវកម្ម៖

- ការប្រឆាំងនឹងបទស៊ីសំណូក អំពើពុករលួយ និងការគេចពន្ធ៖ ប្រព្រឹត្តដោយសុចរិត និងអនុវត្តតាមច្បាប់ស្តីពីការប្រឆាំងនឹងបទស៊ីសំណូក និងអំពើពុករលួយ។
- អំណោយ  និងបដិសណ្ឋារកិច្ច៖  កុំផ្តល់ ឬទទួលយកអំណោយ ការជប់លៀង ឬបដិសណ្ឋារកិច្ច ដែលគេយល់ថា ឬអាចយល់ថា ជាការប៉ុនប៉ងធ្វើឲ្យជះឥទ្ធិពលដល់ការសម្រេចចិត្តអាជីវកម្ម។ កុំផ្តល់អំណោយ ឬបដិស-ណ្ឋារកិច្ចដល់មន្ត្រីសាធារណៈ ឬរដ្ឋាភិបាល  លុះត្រាតែស្របច្បាប់ និងមានការឯកភាពជាមុន។
- ទំនាស់ផលប្រយោជន៍៖ ជូនដំណឹងមកយើងខ្ញុំអំពីទំនាស់ផលប្រយោជន៍ជាក់ស្តែង ឬដែលអាចកើតមាន។
- ការរក្សាការសម្ងាត់ និងឯកជនភាព៖ រក្សាព័ត៌មានសម្ងាត់ និងផ្ទាល់របស់យើងខ្ញុំ និងជូនដំណឹងមកយើងខ្ញុំក្នុងករណីមានការរំលោភបំពាន ឬសង្ស័យមានការរំលោភបំពានណាមួយ។
- ការធ្វើទីផ្សារប្រកបដោយការទទួលខុសត្រូវ៖ កុំផ្សព្វផ្សាយ ឬធ្វើទីផ្សារផលិតផលទៅរកអ្នកមិនជក់បារីដែលមានអាយុក្រោម១៨ឆ្នាំ (ឬអាយុអាប្បបរមាស្របច្បាប់ក្នុងស្រុក ប្រសិនបើអាយុច្រើនជាងនេះ)។ អនុវត្តតាមស្តង់ដារទីផ្សាររបស់ Imperial Brands ក្នុងករណីដែលអាចធ្វើទៅបាន។
- ពាណិជ្ជកម្មខុសច្បាប់៖ កុំចូលរួម ឬគាំទ្រពាណិជ្ជកម្មខុសច្បាប់។
- ការប្រកួតប្រជែងដោយយុត្តិធម៌ និងការប្រកួតប្រជែងដោយស្មើភាពគ្នា៖  អនុវត្តតាមច្បាប់ស្តីពីការប្រកួតប្រជែងជាធរមាន។ សូមកុំចែកចាយព័ត៌មានជាកម្មសិទ្ធិ ឬការសម្ងាត់របស់យើងខ្ញុំ។
- ទណ្ឌកម្ម និងការគ្រប់គ្រងការនាំចេញ៖ ឈ្វេងយល់ និងអនុវត្តតាមច្បាប់ស្តីពីទណ្ឌកម្ម និងការគ្រប់គ្រងការនាំចេញពាក់ព័ន្ធនឹងអាជីវកម្មរបស់អ្នក និងការផ្គត់ផ្គង់ទំនិញ និងសេវាណាមួយមកឲ្យ Imperial Brands។

## សិទ្ធិមនុស្ស និងភាពចម្រុះ សមធម៌ និងបរិយាបន្ន (DEI)៖

- ពលកម្មកុមារ៖ អ្នកផ្គត់ផ្គង់មិនត្រូវជួលកុមារអាយុក្រោម ១៣ឆ្នាំមកធ្វើការ និងមិនត្រូវជួលមនុស្សដែលមានអាយុតិចជាងអាយុអប្បបរមាដែលច្បាប់ក្នុងស្រុកអនុញ្ញាតឲ្យធ្វើការនោះទេ។ ការពារកុមារពីការងារគ្រោះថ្នាក់ព្រមទាំង ទាសភាព ការជួញដូរ និងការកេងប្រវ័ញ្ចផ្លូវភេទ។
- ទាសភាព ពលកម្មដោយបង្ខំ និងការជួញដូរមនុស្សក្នុងសម័យទំនើប៖ រាល់ការងារទាំងអស់ត្រូវធ្វើដោយស្ម័គ្រចិត្ត។ មិនត្រូវជួលកម្មករនិយោជិត ផ្អែកលើប្រាក់កម្រៃ ឬធ្វើការដើម្បីដោះបំណុល។ អនុញ្ញាតឲ្យកម្មករនិយោជិតទាំងអស់រក្សាទុកអត្តសញ្ញាណប័ណ្ណ និងឯកសារផ្ទាល់ខ្លួន។ សូមគោរពសេរីភាពនៃចលនា។
- ម៉ោងធ្វើការ ប្រាក់ឈ្នួល និងអត្ថប្រយោជន៍៖ ធានាថាម៉ោងធ្វើការ និងប្រាក់ឈ្នួលសមរម្យ និងស្របតាមច្បាប់ក្នុងស្រុក។ បើកប្រាក់ឈ្នួលឲ្យកម្មករនិយោជិតឲ្យទាន់ពេលវេលា និងអនុញ្ញាតឲ្យមានថ្ងៃឈប់សម្រាករាល់លក្ខខណ្ឌតម្រូវ។
- ការប្រព្រឹត្តដោយយុត្តិធម៌ ភាពចម្រុះ សមធម៌ និងបរិយាបន្ន៖ ប្រព្រឹត្តចំពោះនិយោជិតគ្រប់ដោយសេចក្តីថ្លៃថ្នូរ ការគោរព និងយុត្តិធម៌។ លើកកម្ពស់ភាពចម្រុះ សមធម៌ និងបរិយាបន្ននៅក្នុងការជួលឲ្យធ្វើការ ការលើកម្ពស់ និងតំណាងការគ្រប់គ្រង។
- សេរីភាពនៃសមាគម៖ គោរពសិទ្ធិនិយោជិតដែលចូលរួម ឬបង្កើតសហជីព ឬចរចាជាសមូហភាព។
- យន្តការដោះស្រាយបណ្តឹង៖ ក្នុងករណីអាចធ្វើទៅបាន សូមផ្តល់កម្មករនិយោជិតនូវបណ្តាញ សម្ងាត់មួយដើម្បីរាយការណ៍បណ្តឹង និងបណ្តឹងតវ៉ាដោយមិនភ័យខ្លាចការសងសឹក ឬចងគំនុំអ្វីឡើយ។
- សុខភាព និងសុវត្ថិភាព៖ អនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិស្តីពីសុខភាព និងសុវត្ថិភាពជាធរមាននៅកន្លែងធ្វើការ។ ធានាថា សម្ភារៈបរិក្ខារស្អាត និងមានសុវត្ថិភាព និងផ្តល់ការបណ្តុះបណ្តាល និងឧបករណ៍សមស្របដល់បុគ្គលិកនិយោជិត។

## និរន្តរភាពបរិស្ថាន៖

- នីតិបរិស្ថាន៖  អនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិស្តីពីបរិស្ថានទាក់ទងនឹងអាជីវកម្មរបស់អ្នក។ របាយការណ៍ហេតុការណ៍ ឬស្ថានភាពអសុវត្ថិភាពណាមួយដល់អាជ្ញាធរមូលដ្ឋាន និង/សេវាបញ្ចេញមតិយោបល់របស់ Imperial Brands ។
- ការកែលម្អជាបន្តបន្ទាប់៖ ឈ្វេងយល់អំពីយុទ្ធសាស្ត្រ ESG របស់ Imperial Brands និងស្វែងរវិធីនានាដើម្បីតស៊ូមតិដល់គោលដៅបរិស្ថានរបស់យើង និងការពារភពផែនដី។

# សុចរិតភាពអាជីវកម្ម

ការធ្វើសកម្មភាពប្រកបដោយការទទួលខុសត្រូវ និងសុចរិតភាពបានអនុញ្ញាតឲ្យ Imperial Brands បង្កើត និងទ្រទ្រង់អាជីវកម្មដោយជោគជ័យ។ យើងឲ្យតម្លៃទៅលើភាពជាដៃគូស្មោះត្រង់ និងអាចជឿទុកចិត្តបាន ដែលយើងមានជាមួយអ្នកផ្គត់ផ្គង់ ដែលធ្វើឲ្យយើង និងដៃគូអាជីវកម្មរបស់យើងទទួលខុសត្រូវក្នុងការធ្វើអាជីវកម្មប្រកបដោយវិជ្ជាជីវៈ និងក្រមសីលធម៌។

ក្នុងនាមជាអ្នកផ្គត់ផ្គង់របស់ Imperial Brands យើងរំពឹងថា អ្នកនឹងប្រកាន់ខ្ជាប់នូវស្តង់ដារខាងក្រោម ប៉ុន្តែនៅគ្រប់ករណីទាំងអស់ អ្នកត្រូវតែគោរពតាមច្បាប់ក្នុងស្រុកជាស្តង់ដារអប្បបរមា៖

## ការប្រឆាំងនឹងបទស៊ីសំណូក អំពើពុករលួយ និងការគេចពន្ធ

- រួមគ្នាអនុវត្តវិធីសាស្ត្រមិនអត់ឱនចំពោះការសូកប៉ាន់ និងអំពើពុករលួយ នៅរាល់ទំនាក់ទំនងអាជីវកម្ម និងអនុវត្តតាមច្បាប់ស្តីពីការប្រឆាំងនឹងបទស៊ីសំណូក និងអំពើពុករលួយ។ យើងនឹងប្រើប្រាស់សិទ្ធិរបស់ខ្លួនដើម្បីតម្រូវឲ្យមានវិធានការកែតម្រូវដើម្បីដាក់ពិន័យអ្នកផ្គត់ផ្គង់ដែលពាក់ព័ន្ធនឹងអំពើពុករលួយ រួមមាន ការបញ្ចប់កិច្ចព្រមព្រៀងក្នុងកិច្ចសន្យា។
- មិនត្រូវឲ្យបង់ប្រាក់ ឬទទួលយកសំណូកឡើយ។
- មិនត្រូវឲ្យ ឬផ្តល់របស់មានតម្លៃ (ទោះតិចក្តី ច្រើនក្តី)ទៅបុគ្គលដែលមានបំណងជានា រក្សា ឬសម្របសម្រួលអាជីវកម្មមិនត្រឹមត្រូវ (ដូចជា ការបង់ប្រាក់ដើម្បីបន្ថយពន្ធ ឬពន្ធគយ)។
- រាយការណ៍ក្តីកង្វល់អំពីសំណូក ឬអំពើពុករលួយទៅកាន់ក្រុមអ្នកច្បាប់ ឬក្រុមការងារផ្លូវច្បាប់ក្នុងស្រុកតាមរយៈអ៊ីមែល SpeakUp@impbrands.com ឬដោយប្រើប្រាស់សេវាបញ្ចេញមតិយោបល់លើអនឡាញរបស់យើងជាសម្ងាត់។

## អំណោយ ការជប់លៀង និងបដិសណ្ឋារកិច្ច

- គោលការណ៍ណែនាំស្តីពីអំណោយ និងការជប់លៀងរបស់ Imperial Brands អនុញ្ញាតឲ្យផ្តល់ និងទទួលអំណោយ ការជប់លៀង និងបដិសណ្ឋារកិច្ចដែលសមស្រប និងសមាមាត្រទៅឲ្យ និងពីតតិយជនដើម្បីឲ្យមានសុចន្ទៈនៅក្នុងទំនាក់ទំនងអាជីវកម្មរបស់យើង។
- កុំឲ្យអំណោយ ការជប់លៀង ឬបដិសណ្ឋារកិច្ចដល់និយោជិតរបស់យើង ឬទទួលយកអំណោយ ការជប់លៀង ឬបដិសណ្ឋារកិច្ចដែលមានគោលបំណង ឬអាចត្រូវបានគេយល់ថា ការប៉ុនប៉ងធ្វើឲ្យជះឥទ្ធិពលទៅលើការសម្រេចចិត្តធ្វើអាជីវកម្មដោយមិនត្រឹមត្រូវ។
- មិនត្រូវផ្តល់ជាអំណោយ ការជប់លៀង ឬបដិសណ្ឋារកិច្ចដល់មន្ត្រីសាធារណៈ ឬមន្ត្រីរដ្ឋាភិបាល លើកលែងតែករណីស្របច្បាប់ និងមានការអនុញ្ញាតប៉ុណ្ណោះ។





“រួមគ្នាអនុវត្តវិធីសាស្ត្រមិនអត់ឱនចំពោះការសូកប៉ាន់ និងអំពើពុករលួយ នៅរាល់ទំនាក់ទំនងអាជីវកម្ម និងអនុវត្តតាមច្បាប់ស្តីពីការប្រឆាំងនឹងបទស៊ីសំណូក និងអំពើពុករលួយ”

# សុចរិតភាពអាជីវកម្ម



## ទំនាស់ផលប្រយោជន៍

- ប្រព្រឹត្តដោយសុចរិត និងតម្លាភាព ដោយជូនដំណឹងមកយើងខ្ញុំអំពីទំនាក់ទំនង ការវិនិយោគទុន ការងារ ឬបញ្ហាណាមួយផ្សេងទៀតដែលអាចជាទំនាស់ផលប្រយោជន៍។
- ជូនដំណឹងមកយើងខ្ញុំ ប្រសិនបើអ្នកបានដឹងអំពីទំនាស់ផលប្រយោជន៍ដែលអាចកើតមាន ឬជាក់ស្តែងនៅក្នុងការងារសម្រាប់ពួកយើង (ឧទាហរណ៍ ប្រសិនបើនិយោជិតរបស់ Imperial Brands មានទំនាក់ទំនងហិរញ្ញវត្ថុជាមួយក្រុមហ៊ុនរបស់អ្នក ឬប្រសិនបើនិយោជិតម្នាក់ក្នុងចំណោមនិយោជិតរបស់អ្នកជាប់ពាក់ព័ន្ធនរណាម្នាក់នៅ Imperial Brands)។
- រាយការណ៍ទំនាស់ផលប្រយោជន៍ជាក់ស្តែង ឬដែលអាចកើតមានណាមួយផ្សេងទៀត តាមដែលខ្លួនបានដឹង។

## ការរក្សាការសម្ងាត់ និងឯកជនភាព

- ការពារព័ត៌មានផ្ទាល់ខ្លួន និងអនុវត្តវិធានការសន្តិសុខសមស្របដើម្បីធានាឯកជនភាពជូននិយោជិត អតិថិជន និងអ្នកផ្គត់ផ្គង់ស្របតាម បទប្បញ្ញត្តិស្តីពីកិច្ចការពារទន្នន័យទូទៅរបស់សហភាពអឺរ៉ុប និងច្បាប់ និងបទប្បញ្ញត្តិស្តីពីឯកជនភាពនៃទិន្នន័យ។
- ការពារព័ត៌មានសម្ងាត់របស់ Imperial Brand ដោយចែករំលែកជាមួយដែលអ្នកដែលត្រូវការមើលវា និងអ្នកដែលមានសិទ្ធិមើលវាតែប៉ុណ្ណោះ។
- ជូនដំណឹងមកយើងខ្ញុំភ្លាមៗអំពីករណីបំពានទិន្នន័យដែលសង្ស័យ ឬជាក់ស្តែង ឬប្រសិនបើព័ត៌មានរបស់យើងខ្ញុំត្រូវបានចេញផ្សាយដល់តតិយជនណាមួយដោយគ្មានការអនុញ្ញាតជាមុនពីយើងខ្ញុំ។
- រក្សា និងគោរពកិច្ចព្រមព្រៀងមិនបញ្ចេញព័ត៌មានសម្ងាត់ ឬរក្សាការសម្ងាត់ជាមួយយើងខ្ញុំដើម្បីការពារព័ត៌មានសម្ងាត់។
- បំពេញកិច្ចព្រមព្រៀងកែច្នៃទិន្នន័យ ប្រសិនបើការកែច្នៃព័ត៌មានផ្ទាល់ខ្លួនរបស់និយោជិត អតិថិជន ឬអ្នកផ្គត់ផ្គង់របស់យើងខ្ញុំ។

## ការធ្វើទីផ្សារប្រកបដោយការទទួលខុសត្រូវ

- ផ្សព្វផ្សាយ ឬធ្វើទីផ្សារផលិតផលថ្នាំជក់ដែលងាយឆេះ ឬផលិតផលជំនាន់ក្រោយ (NGP) របស់យើងខ្ញុំទៅរកអ្នកជក់បារីជាមនុស្សពេញវ័យ ឬអ្នកប្រើប្រាស់ផលិតផលនីកូទីនដើម្បីកម្សាន្តអារម្មណ៍ជាមនុស្សពេញវ័យ។ មនុស្សពេញវ័យគឺជាអ្នកប្រើប្រាស់ដែលមានអាយុលើសពី១៨ឆ្នាំ ឬលើសពីអាយុអប្បបរមាក្នុងស្រុកសម្រាប់ការប្រើប្រាស់ផលិតផលទាំងនេះ។
- អនុវត្តស្តង់ដារទីផ្សារ Imperial Brands នៅលើសម្ភារៈ និងសកម្មភាពផ្សព្វពាណិជ្ជកម្ម/ប្រូម៉ូសិនជូនអតិថិជនដែលអ្នកបង្កើតឡើងសម្រាប់យីហោរបស់យើង។ ស្តង់ដារទីផ្សាររបស់យើងខ្ញុំត្រូវកំណត់ជាអាទិភាព លើកលែងតែក្នុងករណីដែលច្បាប់ក្នុងស្រុកតម្រូវឲ្យស្តង់ដារខ្ពស់ជាងនេះ។

## ពាណិជ្ជកម្មខុសច្បាប់

- មិនត្រូវចូលរួម ឬគាំទ្រពាណិជ្ជកម្មខុសច្បាប់ក្នុងទម្រង់ណាមួយ និងសហការជាមួយអាជ្ញាធរដើម្បីជួយទប់ស្កាត់ផលិតផលខុសច្បាប់មិនឲ្យរកឃើញមធ្យោបាយចូលក្នុងទីផ្សារស្របច្បាប់។
- អនុវត្តតាមគោលនយោបាយស្តីពីអនុលោមភាពផ្គត់ផ្គង់ផលិតផលរបស់ Imperial Brands។
- រាយការណ៍មកយើងខ្ញុំនូវករណីសង្ស័យណាមួយទាក់ទងនឹងពាណិជ្ជកម្មខុសច្បាប់នៃផលិតផលរបស់យើងរួមមាន ការប្រើប្រាស់សម្ភារៈដែលមានយីហោរបស់យើង។

> ជូនដំណឹងមកយើងខ្ញុំភ្លាមៗអំពីករណីបំពានទិន្នន័យដែលសង្ស័យ ឬជាក់ស្តែង ឬប្រសិនបើព័ត៌មានរបស់យើងខ្ញុំត្រូវបានចេញផ្សាយដល់តតិយ ជនណាមួយដោយគ្មានការអនុញ្ញាតជាមុនពីយើងខ្ញុំ



# សុចរិតភាពអាជីវកម្ម

## ការប្រកួតប្រជែងដោយយុត្តិធម៌ និងប្រកួតប្រជែងដោយស្មើភាពគ្នា

- ឈ្វេងយល់ និងអនុវត្តតាមច្បាប់ស្ដីពីការប្រកួតប្រជែងដោយយុត្តិធម៌ជាធរមាន នៅលើទីផ្សារដែលអ្នកធ្វើប្រតិបត្តិការ។
- គ្រាន់តែធ្វើការជាមួយអ្នកប្រកួតប្រជែងរបស់យើងខ្ញុំក៏អាចបង្កជាទំនាស់ផលប្រយោជន៍ណាមួយ និងក្នុងករណីសមស្រប ត្រូវចាត់វិធានការនានាដើម្បីការពារព័ត៌មានសម្ងាត់របស់ Imperial Brands និងគោរពច្បាប់ស្ដីពីការប្រកួតប្រជែង។
- មិនត្រូវពិភាក្សាប្រធានបទរសើបពាក់ព័ន្ធនឹងពាណិជ្ជកម្មជាមួយអ្នកប្រកួតប្រជែងរបស់យើងខ្ញុំ ដូចជា ថ្លៃដើមជាគុចូល ការកំណត់តម្លៃ លក្ខខណ្ឌនៃពាណិជ្ជកម្ម និងការសម្ពោធផលិតផលថ្មី។
- មិនត្រូវដើរតួជាអន្តរការីរវាងយើងខ្ញុំ និងអ្នកប្រកួតប្រជែងរបស់យើងខ្ញុំ រួមទាំងមិនត្រូវចែករំលែកការសម្ងាត់ពាណិជ្ជកម្ម ឬព័ត៌មានសម្ងាត់ផ្សេងទៀតរបស់អ្នកប្រកួតប្រជែងយើងខ្ញុំមកឲ្យពួកយើង។

## ទណ្ឌកម្ម និងការគ្រប់គ្រងការនាំចេញ

- យល់ដឹងអំពីការត្រួតពិនិត្យការនាំចេញ និងការរឹតបន្តឹងពាណិជ្ជកម្មដែលពាក់ព័ន្ធនឹងអាជីវកម្មរបស់អ្នក។
- អនុវត្តតាមច្បាប់ស្ដីពីទណ្ឌកម្មជាធរមាន និងការត្រួតពិនិត្យការនាំចេញនៅក្នុងការងារណាមួយដែលត្រូវបានអនុវត្តសម្រាប់ Imperial Brands។

បញ្ចេញមតិយោបល់៖ លើកឡើងនូវក្ដីកង្វល់របស់អ្នកជាសម្ងាត់ ដោយប្រើប្រាស់សេវាបញ្ចេញមតិយោបល់លើអនឡាញ។ គោលនយោបាយ បញ្ចេញមតិយោបល់ ផ្ដល់ការណែនាំបន្ថែមអំពីការរាយការណ៍ក្ដីកង្វល់ និងព័ត៌មាននៅលើគោលនយោបាយស្ដីពីការមិនចងគំនុំរបស់យើងខ្ញុំ។

បញ្ចេញមតិយោបល់៖



“ឈ្វេងយល់ និងអនុវត្តតាមច្បាប់ស្ដីពីការប្រកួតប្រជែងដោយយុត្តិធម៌ជាធរមាន នៅលើទីផ្សារដែលអ្នកធ្វើប្រតិបត្តិការ”

# សិទ្ធិមនុស្ស

## យើងខ្ញុំគិតគូរលើសុវត្ថិភាព សេចក្តីថ្លៃថ្នូរ និងសុខុមាលភាពរបស់និយោជិត ដៃគូអាជីវកម្មរបស់យើង និងសហគមន៍ដែលយើងប្រកបអាជីវកម្ម។

យើងខ្ញុំគោរពសិទ្ធិមនុស្សនៅរាល់ប្រតិបត្តិការរបស់យើង និងប្តេជ្ញាចៀសវាងរាល់ទម្រង់នៃពលកម្មកុមារ ដោយបង្ខំ ឬការងារដោះបំណុល ព្រមទាំងការពារសេរីភាពនៃសមាគម។ យើងខ្ញុំគោរពតាមសេចក្តីប្រកាសជាសាកល ស្តីពីសិទ្ធិមនុស្ស  គោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស និងសេចក្តីប្រកាសរបស់អង្គការអន្តរជាតិខាងការងារស្តីពីគោលការណ៍ជាមូលដ្ឋាន និងសិទ្ធិនៅកន្លែងធ្វើការ។ សម្រាប់ព័ត៌មានបន្ថែម សូមមើល Imperial Brands Human Rights Policy. ។ យើងរំពឹងថា អ្នកផ្គត់ផ្គង់របស់យើងនឹងរួមគ្នាប្តេជ្ញាធ្វើការដើម្បីសិទ្ធិមនុស្ស និងធ្វើការជាមួយយើងខ្ញុំដើម្បីធានាបាននូវកន្លែងធ្វើការ និងសហគមន៍ប្រកបដោយយុត្តិធម៌ និងសុវត្ថិភាព។



ក្នុងនាមជាអ្នកផ្គត់ផ្គង់របស់ Imperial Brands យើងរំពឹងថា អ្នកប្រកាន់ខ្ជាប់នូវស្តង់ដារខាងក្រោម ប៉ុន្តែនៅរាល់ករណីទាំងអស់ អ្នកត្រូវតែអនុវត្តតាមច្បាប់ក្នុងស្រុកជាស្តង់ដារអប្បបរមា៖

### ពលកម្មកុមារ

- មិនត្រូវជួលកុមារអាយុក្រោម១៣ឆ្នាំមកធ្វើការ និងមិនត្រូវជួលមនុស្សដែលមានអាយុតិចជាងអាយុអប្បបរមាដែលច្បាប់ក្នុងស្រុកអនុញ្ញាតឲ្យធ្វើការនោះទេ។
- អាចអនុញ្ញាតឲ្យធ្វើការងារស្រាលនៅក្នុងម៉ោងដែលកំណត់ដោយច្បាប់ជាតិ ឲ្យតែការងារនោះមិនប៉ះពាល់ដល់ការរៀនសូត្រ សុខភាព និងការអភិវឌ្ឍខ្លួន។
- មិនត្រូវជួលមនុស្សអាយុក្រោម១៨ឆ្នាំឲ្យធ្វើការនៅកន្លែងគ្រោះថ្នាក់ (ដូចបានកំណត់ដោយច្បាប់ក្នុងស្រុក)។
- ការពារកុមារពីទាសភាព ការជួញដូរ និងការកេងប្រវ័ញ្ចផ្លូវភេទ។

### ទាសភាព ពលកម្មដោយបង្ខំ និងការជួញដូរមនុស្សក្នុងសម័យទំនើប

- ជួលកម្មករនិយោជិតដោយស្ម័គ្រចិត្តផ្អែកលើខចែង និងលក្ខខណ្ឌដែលបានដឹង និងយល់នៅពេលជ្រើសរើស។ គួរផ្តល់កិច្ចសន្យាជាលាយលក្ខណ៍អក្សរ តាមសំណើ និងតម្រូវដោយច្បាប់ក្នុងស្រុក។
- មិនត្រូវជួលកម្មករនិយោជិតផ្អែកលើថ្លៃសេវាជួល ថ្លៃឲ្យការងារធ្វើ ឬធ្វើការដោះបំណុលប្រភេទណាមួយឡើយ។
- អនុញ្ញាតឲ្យកម្មករនិយោជិតទាំងអស់រក្សាទុកកម្មសិទ្ធិនៃឯកសារផ្ទាល់ខ្លួន រួមមាន អត្តសញ្ញាណប័ណ្ណ និងលិខិតឆ្លងដែន។ គោរពសេរីភាពនៃចលនា។

> យើងខ្ញុំគិតគូរដល់សុវត្ថិភាព សេចក្តីថ្លៃថ្នូរ និងសុខុមាលភាពរបស់និយោជិត ដៃគូអាជីវកម្មរបស់យើង និងសហគមន៍ដែលយើងប្រកបអាជីវកម្ម

# សិទ្ធិមនុស្ស និង DEI

### ម៉ោងធ្វើការ ប្រាក់ឈ្នួល និងអត្ថប្រយោជន៍

- ធានាថាម៉ោងធ្វើការ និងប្រាក់ឈ្នួលសមរម្យ និងស្របច្បាប់ដែលស្របតាមច្បាប់ជាតិ ឬក្នុងស្រុក ស្តង់ដារឧស្សាហកម្ម ឬកិច្ចព្រមព្រៀងសមូហភាពដែលបានធ្វើឡើងជាមួយកម្មករនិយោជិត ដោយផ្តល់កិច្ចការពារកាន់ប្រសើរឡើង។
- បើកប្រាក់ឈ្នួលទាន់ពេលវេលា និងគ្រប់ចំនួនដោយធានាថា ការកាត់ប្រាក់ឈ្នួលណាមួយគឺស្របច្បាប់ យុត្តិធម៌ តម្លាភាព និងត្រូវបានកត់ត្រាទុក។
- ឲ្យកម្មករនិយោជិតបានឈប់សម្រាកដោយយោងតាមច្បាប់ និងបទប្បញ្ញត្តិក្នុងស្រុក រួមមាន ការសម្រាក ថ្ងៃឈឺ ថ្ងៃឈប់សម្រាក និងថ្ងៃបុណ្យជាតិ។
- ធានាថា ការងារបន្ថែម ឬថែមម៉ោងត្រូវធ្វើឡើងដោយស្ម័គ្រចិត្តស្របច្បាប់ និងទទួលបានសំណងស្របតាមច្បាប់ជាធរមាន។

### ការប្រព្រឹត្តដោយយុត្តិធម៌ ភាពចម្រុះ សមធម៌ និង បរិយាបន្ន

- ធ្វើយ៉ាងណាឲ្យមានកន្លែងធ្វើការមួយដែលគ្មានអំពើហិង្សា ការបង្ខិតបង្ខំ ការបំភិតបំភ័យ ការបៀតបៀន ការបៀតបៀនផ្លូវភេទ ការរើសអើង ឬអាកប្បកិរិយាបន្ទាបបន្ថោកផ្សេងៗក្នុងទម្រង់ណាមួយឡើយ។
- ប្រព្រឹត្តចំពោះនិយោជិតគ្រប់រូបដោយសេចក្តីថ្លៃថ្នូរ ការគោរព និងយុត្តិធម៌។
- លើកកម្ពស់ភាពចម្រុះ សមធម៌ និងបរិយាបន្ននៅក្នុងការងារ ការលើកកម្ពស់ និងតំណាងការគ្រប់គ្រង។
- ឆ្ពោះទៅរកការអនុវត្តលទ្ធកម្មដែលគាំទ្រអ្នកផ្គត់ផ្គង់ផ្សេងៗ ក្នុងករណីអាចធ្វើទៅបាន។

### ការកែលម្អជាបន្តបន្ទាប់៖ ភាពចម្រុះ សមធម៌ និងបរិយាបន្ន

- ការឈានទៅរកកន្លែងធ្វើការដែលកាន់តែមានលក្ខណៈចម្រុះ និងបរិយាបន្នគឺជាការទទួលខុសត្រូវរួមគ្នារបស់យើង។ យើងខ្ញុំកំពុងខិតខំប្រឹងប្រែងក្នុងគោលបំណងសម្រេចឲ្យបានអង្គការមួយដែលកាន់តែមានលក្ខណៈចម្រុះ និងបរិយាបន្ននៅ Imperial Brands និងចង់ឃើញអ្នកផ្គត់ផ្គង់របស់យើងចូលរួមចំណែកជាផ្នែកមួយនៃកិច្ចប្រឹងប្រែងទាំងនោះ។
- យើងលើកទឹកចិត្តឲ្យអ្នកផ្គត់ផ្គង់របស់ Imperial Brands បង្កើតកម្មវិធីផ្ទៃក្នុងដើម្បីវាស់វែង ត្រួតពិនិត្យ និងលើកកម្ពស់ភាពចម្រុះ សមធម៌ និងបរិយាបន្នឲ្យកាន់តែសកម្មថែមទៀតនៅក្នុងអង្គការរបស់ខ្លួន។
- ឈ្វេងយល់បន្ថែមអំពីអ្វីដែលយើងកំពុងធ្វើដើម្បីលើកកម្ពស់ភាពចម្រុះ សមធម៌ និងបរិយាបន្ននៅលើគេហទំព័ររបស់យើងនទីនេះ។

### សេរីភាពនៃសមាគម

- គោរពសិទ្ធិកម្មករនិយោជិតដែលចូលរួម ឬបង្កើតសហជីព ឬក្រុមប្រឹក្សាការងារដើម្បីសម្រេចជ្រើសរើស និងចរចាជារួមដោយគ្មានការភ័យខ្លាចការបំភិតបំភ័យ ឬសងសឹកអ្វីឡើយ។



“យើងខ្ញុំកំពុងខិតខំប្រឹងប្រែងក្នុងគោលបំណងសម្រេចឲ្យបានអង្គការមួយដែលកាន់តែមានលក្ខណៈចម្រុះ និងបរិយាបន្ននៅ Imperial Brands និងចង់ឃើញអ្នកផ្គត់ផ្គង់របស់យើងចូលរួមចំណែកជាផ្នែកមួយនៃកិច្ចប្រឹងប្រែងទាំងនោះ”



# សិទ្ធិមនុស្ស និង DEI

## យន្តការដោះស្រាយបណ្តឹង

- ក្នុងករណីអាចធ្វើទៅបាន សូមផ្តល់យន្តការផ្ទៃក្នុងជាសម្ងាត់ដល់កម្មករនិយោជិតដើម្បីដាក់ពាក្យបណ្តឹង និងបណ្តឹងតវ៉ា ដោយមិនភ័យខ្លាចការសងសឹក ឬចងគំនុំអ្វីឡើយ។ មានគោលបំណងបង្កើតប្រព័ន្ធដ៏មានប្រសិទ្ធភាពមួយ និងដំណើរការផ្ទៃក្នុងដើម្បីស៊ើបអង្កេត និងដោះស្រាយក្តីកង្វល់នានា ប្រកបដោយតម្លាភាព យុត្តិធម៌ និងឆាប់រហ័ស។
- ក្នុងករណីមិនអាចធ្វើទៅបាន សូមលើកទឹកចិត្តឲ្យកម្មករនិយោជិតរាយការណ៍ក្តីកង្វល់ទាំងនោះមកកាន់ Imperial Brands ដោយផ្ទាល់ ឬមកកាន់អ៊ីមែល SpeakUp@impbrands.com ឬដោយប្រើប្រាស់សេវាបញ្ចេញមតិយោបល់ជាសម្ងាត់របស់យើង។

## សុខភាព និងសុវត្ថិភាព

- អនុវត្តតាមច្បាប់ និងបទបញ្ញត្តិស្តីពីសុខភាព និងសុវត្ថិភាពជាធរមាន នីតិកម្ម និងស្តង់ដារនានា។
- ផ្តល់រាល់ការបណ្តុះបណ្តាលស្តីពីសុខភាព និងសុវត្ថិភាពដ៏ចាំបាច់ ឧបករណ៍ និងសម្លៀកបំពាក់ការងារ។
- មិនគួរឲ្យមនុស្សដែលមិនធ្លាប់បានទទួលការបណ្តុះបណ្តាល មនុស្សអាយុក្រោម១៨ឆ្នាំ ស្ត្រីមានផ្ទៃពោះ ម្តាយបំបៅដោះកូន ឬមនុស្សចាស់ទៅធ្វើការនៅកន្លែងគ្រោះថ្នាក់ឡើយ។
- កាត់បន្ថយយ៉ាងណាកុំឲ្យកម្មករ តតិយជន និងសហគមន៍ប្រឈមនឹងវត្ថុធាតុ និងសារធាតុបង្កគ្រោះថ្នាក់។
- ធានាថា កន្លែងស្នាក់នៅ ការដឹកជញ្ជូន ឬគ្រឿងបរិក្ខារសហគមន៍ដែលផ្តល់ជូនកម្មករនិយោជិតមានសុវត្ថិភាព ស្អាត និងសក្តិសម។
- រាយការណ៍ភ្លាមៗនូវរាល់ក្តីកង្វល់សុខភាព និងសុវត្ថិភាពពាក់ព័ន្ធនឹងទំនាក់ទំនងរបស់អ្នកជាមួយយើងខ្ញុំ ដើម្បីទាក់ទងផ្នែកលទ្ធកម្ម Imperial Brands របស់អ្នក ឬដោយប្រើប្រាស់សេវាបញ្ចេញមតិយោបល់លើអនឡាញរបស់អ្នក។

## ការកែលម្អជាបន្តបន្ទាប់៖ កន្លែងធ្វើការកាន់តែមានសុវត្ថិភាព

- យើងរំពឹងថា អ្នកផ្គត់ផ្គង់របស់ Imperial Brands នឹងចូលរួមជាមួយយើងក្នុងការបន្តការងារឆ្ពោះទៅរកកន្លែងធ្វើការ និងសហគមន៍កាន់តែមានសុវត្ថិភាព។ បន្ថែមលើលក្ខខណ្ឌតម្រូវអប្បបរមាទាំងនេះ យើងលើកទឹកចិត្តឲ្យអ្នកសុំរាល់លិខិតបញ្ជាក់សុខភាព និងសុវត្ថិភាពពាក់ព័ន្ធដែលអាចអនុវត្តចំពោះអាជីវកម្មរបស់អ្នក និងធ្វើការដើម្បីកំណត់ហានិភ័យ និងមុខសញ្ញាគ្រោះថ្នាក់ដល់សុខភាព និងសុវត្ថិភាព តាមរយៈការត្រួតពិនិត្យ និងសវនកម្មជាប្រចាំលើបរិក្ខារ ឧបករណ៍ និងដំណើរការនានា។
- និយាយប្រាប់ពួកយើងមក ប្រសិនបើអ្នកមានអារម្មណ៍ថា អាចធ្វើឲ្យផ្នែកណាមួយនៃការងាររបស់យើងកាន់តែមានសុវត្ថិភាពថែមទៀត។
- សូមមើល គោលនយោបាយស្តីពីសុខភាព សុវត្ថិភាពនិងសុខុមាលភាព នៅលើគេហទំព័ររបស់យើងខ្ញុំដើម្បីឈ្វេងយល់បន្ថែមអំពីការប្តេជ្ញារបស់យើងខ្ញុំដើម្បីសម្រេចបាន ស្តង់ដារសុខភាព សុវត្ថិភាព និងសុខុមាលភាពលំដាប់ពិភពលោក។



> “មិនគួរឲ្យមនុស្សដែលមិនធ្លាប់បានទទួលការបណ្តុះបណ្តាល មនុស្សអាយុក្រោម១៨ឆ្នាំ ស្ត្រីមានផ្ទៃពោះ ម្តាយបំបៅដោះកូន ឬមនុស្សចាស់ទៅធ្វើការនៅកន្លែងគ្រោះថ្នាក់ឡើយ”





# និរន្តរភាពបរិស្ថាន

យើងប្តេជ្ញាស្វែងរកមធ្យោបាយធ្វើការប្រកបដោយនិរន្តរភាពបរិស្ថាន ពោលគឺ វាជារឿងដ៏ត្រឹមត្រូវមួយដែលយើងត្រូវធ្វើដើម្បីប្រជាជន អាជីវកម្ម និងភពផែនដីរបស់យើង។

នៅក្នុងប្រតិបត្តិការរបស់យើង យើងមានគោលបំណងសម្រេចឲ្យបាននូវ៖

- គ្មានការបំភាយឧស្ម័នផ្ទះកញ្ចក់នៅត្រឹមឆ្នាំ២០៤០
- គ្មានសំណល់នៅកន្លែងចាក់សំរាមនៅត្រឹមឆ្នាំ២០២៥
- គ្មានការកាប់បំផ្លាញព្រៃឈើនៅត្រឹមឆ្នាំ២០២៥

អ្នកអាចឈ្វេងយល់បន្ថែមអំពីការប្តេជ្ញា និងគោលដៅបរិស្ថានរបស់យើងនៅក្នុង យុទ្ធសាស្ត្រ ESG របស់ Imperial Brands។.

យើងស្នើសុំឲ្យអ្នកចូលរួមជាមួយយើងនៅក្នុងដំណើរការនេះដើម្បីកាត់បន្ថយផលប៉ះពាល់បរិស្ថាននៃអាជីវកម្មរបស់យើងដោយគ្រប់គ្រងផលប៉ះពាល់បរិស្ថានផ្ទាល់របស់អ្នកប្រកបដោយការទទួលខុសត្រូវ។ ក្នុងនាមជាអ្នកផ្គត់ផ្គង់របស់ Imperial Brands អ្នកត្រូវតែបំពេញតាមស្តង់ដារខាងក្រោមជាអប្បបរមា៖

- អនុវត្តរាល់ច្បាប់ និងបទប្បញ្ញត្តិស្តីពីនីតិបរិស្ថានដែលអាចអនុវត្តបានចំពោះអាជីវកម្មរបស់អ្នក។
- ចាត់វិធានការដោះស្រាយតាមតម្រូវការ រាយការណ៍ទៅអាជ្ញាធរពាក់ព័ន្ធ ប្រសិនបើចាំបាច់ និងជូនដំណឹងមកយើងខ្ញុំអំពីហេតុការណ៍ណាមួយពាក់ព័ន្ធនឹងអាជីវកម្មរបស់យើងដែលមាន ឬអាចមានផលប៉ះពាល់បរិស្ថានធ្ងន់ធ្ងរ។
- ជូនដំណឹងមកយើងខ្ញុំអំពីដំណើរការ ឬលក្ខខណ្ឌណាមួយពាក់ព័ន្ធនឹងអាជីវកម្មរបស់យើងដែលអាចបង្កគ្រោះថ្នាក់ ឬដែលមាន ឬមានផលប៉ះពាល់ធ្ងន់ធ្ងរទៅលើបរិស្ថាន។





# និរន្តរភាពបរិស្ថាន

### ការកែលម្អជាបន្តបន្ទាប់៖ និរន្តរភាពបរិស្ថាន

យើងលើកទឹកចិត្តឲ្យអ្នកអនុវត្តឲ្យលើសពីស្តង់ដារអប្បបរមារបស់យើងខ្ញុំ និងដាក់ចេញនូវគំនិតផ្តួចផ្តើមដែលអាចជួយលើកកម្ពស់គោលដៅបរិស្ថានរបស់យើង និងការពារភពផែនដីរបស់យើងនៅក្នុងចំណុចខាងក្រោម៖

### ការបំភាយ

- កាត់បន្ថយវិសាលភាពនៃការបំភាយទី១, ២ និង៣នៅក្នុងប្រតិបត្តិការអាជីវកម្មរបស់អ្នក។

### សំណល់

- កាត់បន្ថយផលប៉ះពាល់នៃសំណល់ដែលបង្កើតឡើងដោយប្រតិបត្តិការអាជីវកម្មរបស់អ្នក។
- គ្រោងរៀបចំផលិតផលដោយគិតគូរដល់ឱកាសក្នុងការកាត់បន្ថយ សំណល់។
- បង្កើនលទ្ធភាពកែច្នៃ និងប្រើប្រាស់ឡើងវិញសម្រាប់ការវេចខ្ចប់។
- ធ្វើការសកម្មដើម្បីកាត់បន្ថយសំណល់នៅកន្លែងចាក់សំរាម និងធានានូវការទុកដាក់ ឬកែច្នៃសំណល់ប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាព។

### សារធាតុផ្សំ វត្ថុធាតុដើម និងវិធីសាស្ត្រប្រកបដោយនិរន្តរភាព

- កាត់បន្ថយការពឹងផ្អែកទៅលើវត្ថុធាតុមិនទាន់ប្រើប្រាស់ លើកលែងតែករណីចាំបាច់
- ត្រួតពិនិត្យ និងលើកកម្ពស់ការប្រើប្រាស់ធនធានធម្មជាតិ។
- ប្តូរពីការប្រើប្រាស់គីមីកសិកម្មដែលជាតិពុល និងគ្រោះថ្នាក់មកប្រើប្រាស់ជម្រើសបែបធម្មជាតិ និងមិនបង្កគ្រោះថ្នាក់ តាមតែអាចធ្វើទៅបាន។
- ធ្វើការជាមួយអ្នកផ្គត់ផ្គង់របស់អ្នកដើម្បីធានាថា ធនធានធម្មជាតិនានាត្រូវបានប្រើប្រាស់ប្រកបដោយការទទួលខុសត្រូវ។

### ការកាប់បំផ្លាញព្រៃឈើ និងជីវចម្រុះ

- ស្វះស្វែងកាត់បន្ថយផលប៉ះពាល់នៃការកាប់បំផ្លាញព្រៃឈើនៅក្នុងប្រតិបត្តិការរបស់អ្នក។
- រកវិធានការដើម្បីការពារ និងលើកស្ទួយជីវចម្រុះ រួមមាន ការទប់ស្កាត់ការបាត់បង់ជម្រក និងការពារពពួកសត្វដែលជិតផុតពូជ ឬរងការគំរាមកំហែង។
- ធានាអនុលោមតាមច្បាប់ស្តីពីការយកចិត្តទុកដាក់ខ្ពស់លើការកាប់បំផ្លាញព្រៃឈើជាធរមានសម្រាប់ផលិតផលដែលមានហានិភ័យដោយការកាប់បំផ្លាញព្រៃឈើ និងរៀបចំដំណើរការអនុវត្តការយកចិត្តទុកដាក់ខ្ពស់ និងដោះស្រាយហានិភ័យ ឬបញ្ហានានានៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់របស់អ្នកដោយយោងទៅលើច្បាប់ស្តីពីការយកចិត្តទុកដាក់ខ្ពស់ថ្មី new due diligence laws.

### គោលនយោបាយ ការពិនិត្យតាមដាន និងរាយការណ៍

- បង្កើតគោលនយោបាយបរិស្ថាន និងប្រព័ន្ធគ្រប់គ្រង។
- កំណត់សូចនាករសមិទ្ធកម្មគន្លឹះដើម្បីវាស់វែង ត្រួតពិនិត្យ និងកែលម្អជាបន្តបន្ទាប់នូវសមិទ្ធកម្មបរិស្ថានស្របតាមគំនិតផ្តួចផ្តើមកំណត់គោលដៅដូចជា គំនិតផ្តួចផ្តើម គោលដៅផ្អែកលើវិទ្យាសាស្ត្រ។
- ចូលរួមក្នុងការដាក់ជូនប្រចាំឆ្នាំទៅ គម្រោង Carbon Disclosure Project.





# ការផ្ទៀងផ្ទាត់ និងការកែលម្អជាបន្តបន្ទាប់

## យើងខ្ញុំរំពឹងថា អ្នកផ្គត់ផ្គង់របស់យើងនឹងអនុវត្តស្តង់ដារដូចមានចែងនៅក្នុងក្រមនេះ រួមមាន ការដាក់ឲ្យអនុវត្តដំណើរការ និងការត្រួតពិនិត្យដ៏ចាំបាច់ និងរាយការណ៍វឌ្ឍនភាពដែលអាចវាស់វែងបាន។

ជាផ្នែកមួយនៃវិធីសាស្ត្រកែលម្អជាបន្តបន្ទាប់របស់យើងក្នុងការអនុវត្តស្តង់ដារ យើងនឹងធ្វើការជាមួយអ្នក ដើម្បីធ្វើការអនុវត្តឲ្យបានប្រសើរឡើង និងដោះស្រាយបញ្ហាប្រឈមនានានៅក្នុងករណីបុគ្គល។ យើងនឹង មិនទទួលយក ឬមិនអើពើនឹងសកម្មភាពដែលយើងសង្ស័យថា អាចបំពានលើក្រមនេះបានឡើយ។

## ក្នុងនាមជាអ្នកផ្គត់ផ្គង់របស់ Imperial Brands យើងខ្ញុំរំពឹងថា អ្នកនឹង៖

- សហការដោយពិនិត្យឡើងវិញ វាយតម្លៃ ឬធ្វើសវនកម្មផ្ទៃក្នុង ឬខាងក្រៅតាមសំណើ នៃអាជីវកម្មរបស់អ្នកដែលពាក់ព័ន្ធអនុលោមភាពនៃក្រមនេះ។
- សហការជាមួយយើងខ្ញុំក្នុងការព្រមព្រៀង និងអនុវត្តសកម្មភាពនានាឲ្យបានទាន់ពេលវេលាដើម្បីកាត់បន្ថយ ឬកែតម្រូវចំណុចខ្វះខាត ឬបញ្ហានានា ប្រសិនបើរកឃើញចំណុចខ្វះខាត ឬបញ្ហាណាមួយកើតមាន។

អ្នកផ្គត់ផ្គង់ត្រូវយល់ថា ការអនុវត្តផ្ទុយពីស្តង់ដារដូចមានចែងនៅក្នុងក្រមនេះ និងឆន្ទៈរបស់អ្នកផ្គត់ផ្គង់ក្នុងការកែតម្រូវចំណុចខ្វះខាតណាមួយគឺជាកត្តាចម្បងនៅក្នុងការសម្រេចចិត្តរបស់យើងខ្ញុំក្នុង ការចូលរួម ឬបន្តទំនាក់ទំនងអាជីវកម្មជាមួយអ្នកផ្គត់ផ្គង់របស់ Imperial Brands។ នៅក្នុងករណីខ្លះ ការមិនអនុលោមតាមក្រមនេះ នឹងត្រូវឲ្យចាត់វិធានការកែតម្រូវ និងអាចចាត់ចូលក្នុងករណីបញ្ចប់កិច្ចព្រមព្រៀងក្នុងកិច្ចសន្យា។





កាន់តែរឹងមាំ កាន់តែប្រសើរឡើងទាំងអស់គ្នាជាមួយអ្នក ផ្គត់ផ្គង់របស់យើង

# បញ្ចេញមតិយោបល់

យើងខ្ញុំលើកទឹកចិត្តឲ្យមានការបើកទូលាយ និងតម្លាភាពនៅក្នុងImperial Brands និងជាមួយអ្នកផ្គត់ផ្គង់របស់យើង។ ប្រសិនបើយើងខ្ញុំមានក្តីកង្វល់ ឬសង្ស័យកើតមានករណីបំពានច្បាប់ ឬក្រមប្រតិបត្តិរបស់អ្នកផ្គត់ផ្គង់ យើងខ្ញុំចង់ឲ្យអ្នកនិយាយចេញមក។

## ទាក់ទងមកពួកយើង

Imperial Brands Plc, 121 Winterstoke Road, Bristol
BS3 2LL, United Kingdom
Tel: +44 ( 0 ) 117 963 6636
Email: SpeakUp@impbrands.com

ITG Brands
មានបណ្តាញរាយការណ៍ដោយឡែកមួយ៖

ITG Brands បញ្ចេញមតិយោបល់
714 Green Valley Road
Greensboro, NC 27408
Tel: +1 866 447 6092

## បញ្ចេញមតិយោបល់

សូមលើកឡើងនូវមតិយោបល់របស់អ្នកជាសម្ងាត់ដោយប្រើប្រាស់សេវាបញ្ចេញមតិយោបល់តាមអនឡាញរបស់យើងខ្ញុំ។ គោលនយោបាយបញ្ចេញមតិយោបល់ផ្តល់ការណែនាំបន្ថែមសម្រាប់រាយការណ៍អំពីក្តីកង្វល់ និងព័ត៌មានលើគោលនយោបាយមិនចងគំនុំរបស់យើងខ្ញុំ។

បញ្ចេញមតិយោបល់៖

## ព័ត៌មាន និងធនធានបន្ថែម

សូមមើលគេហទំព័រ Imperial Brands www.imperialbrandsplc.com



